# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៦ អនក្រ.បក

## សេចក្តីសម្រេច
## ស្តីពី
## ការកំណត់ការធ្វើអាជីវកម្មខ្សាច់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ ១ :** ដើម្បីការពារបាននូវលំនឹងបរិស្ថានធម្មជាតិ ទាំងដែនទឹកសាប ទាំងដែនសមុទ្រ ការធ្វើអាជីវកម្មខ្សាច់គ្រប់ប្រភេទក្នុងក្របខ័ណ្ឌទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម :

**១- ចំពោះការធ្វើអាជីវកម្មខ្សាច់ទឹកសាប :**

ខ្សាច់ទឹកសាបដែលមាននៅក្នុងទន្លេ ស្ទឹង ព្រែក អូរ... អាចអនុញ្ញាតឱ្យធ្វើអាជីវកម្មបានក្នុងករណី :

-តែការធ្វើអាជីវកម្មនេះ គឺដើម្បីបម្រើដល់តម្រូវការប្រើប្រាស់ក្នុងស្រុកតែប៉ុណ្ណោះ

-អាចអនុញ្ញាតឱ្យធ្វើអាជីវកម្មបានតែនៅកន្លែងណា ដែលបច្ចេកទេសពិនិត្យទៅឃើញថាមានខ្សាច់ដុះកកស្ទះជាហេតុបណ្តាលឱ្យប៉ះពាល់ដល់ផ្លូវទឹកតែប៉ុណ្ណោះ

-បញ្ឈប់ការនាំខ្សាច់ចេញទៅក្រៅប្រទេស ។

www.pheakdeylaw.com

**២- ចំពោះការធ្វើអាជីវកម្មខ្សាច់សមុទ្រ :**

-មិនអនុញ្ញាតអោយធ្វើអាជីវកម្មលើធនធានខ្សាច់សមុទ្រ ទោះជាទីតាំងនោះស្ថិតនៅឆ្ងាយពីឆ្នេរ ឬពីកោះក៏ដោយ ។

-អាចអនុញ្ញាតបានចំពោះតែកន្លែងណាដែលមានខ្សាច់ដុះគោកកក់និងអាចបំពេញវិញបានជាលក្ខណៈធម្មជាតិ តែត្រូវបំពេញល័ក្ខខ័ណ្ឌបច្ចេកទេសជាមុន ។

**ប្រការ ២ :** គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ត្រូវធ្វើការត្រួតពិនិត្យឡើងវិញជាបន្ទាន់ ទៅតាមការកំណត់នៃការធ្វើអាជីវកម្មដូចមានចែងក្នុងប្រការ ១ ដើម្បីធ្វើរបាយការណ៍ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីពិនិត្យ និងសំរេច ។

**ប្រការ ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសំរេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល :__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ